**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ១៨៥០ សជណ

ថ្ងៃ ចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២១

## ជម្រាបជូន

- **ឯកឧត្តមប្រធានក្រុមប្រឹក្សារាជធានី ខេត្ត**
- **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** ៖ ស្តីពីការពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

**<u>យោង</u>** ៖- អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារដ្ឋបាល
- លិខិតលេខ៦៥៦ សជណ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យដំណើរការការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**ជ្រាបថា បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចបង្កើតឱ្យមានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រសួងមហាផ្ទៃបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវការិយាល័យនេះកាលពីដើមឆ្នាំ២០២០។ កន្លងមកក្រសួងមហាផ្ទៃបានពិនិត្យឃើញថា ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តភាគច្រើនបានដំណើរការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹង ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដោយរលូន និងប្រកបដោយប្រសិទ្ធភាព ដោយសារមានការយកចិត្តទុកដាក់គាំទ្រពីសំណាក់ថ្នាក់ដឹកនាំនៃរដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃក៏បានសង្កេតឃើញដែរថា ការិយាល័យប្រជាពលរដ្ឋមួយចំនួនទៀត មិនទាន់អាចដំណើរការអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី និងភារកិច្ចដែលមានកំណត់នៅក្នុងលិខិតបទដ្ឋាននៅឡើយ ដោយសារជួបប្រទះនូវបញ្ហាប្រឈមមួយចំនួននៅក្នុងដំណើរការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន។



ទីស្តីការក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ៧២៦ ០៥២, ០២៣ ៧២៦ ០៥៣
ទូរសារ: ០២៣ ៧២៦០៥២, ០២៣ ៧២៦ ០៥៣ E-mail: moi@interior.gov.kh, Website: www.interior.gov.kh

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំរាជធានី ខេត្ត អំពីការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលបានរៀបចំឡើងដោយក្រសួងមហាផ្ទៃកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០កន្លងទៅ ក្រសួងមហាផ្ទៃសូមផ្តល់ការណែនាំមួយចំនួនដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការពង្រឹងការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដូច ខាងក្រោម៖

- រដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យ និងផ្តល់លទ្ធភាពគាំទ្រលើផែនការសកម្មភាពប្រចាំឆ្នាំដែលបានស្នើឡើងដោយប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ អភិបាលរាជធានី ខេត្តត្រូវដាក់បញ្ចូលផែនការសកម្មភាពទាំងនោះ ទៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ស្របតាមខ្លឹមសារមាត្រា២៩ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្តត្រូវផ្តល់ព័ត៌មានត្រឡប់ឱ្យបានជាក់លាក់ អំពីលទ្ធភាពនៃការគាំទ្រថវិកាទៅលើសកម្មភាពរបស់ការិយាល័យប្រជាពលរដ្ឋ ដើម្បីឱ្យប្រធានការិយាល័យបានដឹង និងងាយស្រួលក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន
- នៅពេលអនុម័តគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្តត្រូវពិនិត្យមើល និងធានាថា ផែនការសកម្មភាព និងថវិការបស់ការិយាល័យប្រជាពលរដ្ឋត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សិទ្ធិដល់ប្រធានការិយាល័យប្រជាពលរដ្ឋក្នុងការគ្រប់គ្រង និងចាត់ចែងបុគ្គលិក ដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារនៅក្នុងរចនាសម្ព័ន្ធរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ប្រធានការិយាល័យប្រជាពលរដ្ឋត្រូវចាត់ចែង និងបែងចែកតួនាទី ភារកិច្ច ដល់បុគ្គលិករបស់ខ្លួនឱ្យបានច្បាស់លាស់។ ក្នុងករណីដែលបុគ្គលិកមិនបានមកបំពេញការងារតាមតួនាទី ភារកិច្ចដែលបានកំណត់ ប្រធានការិយាល័យប្រជាពលរដ្ឋត្រូវអនុវត្តវិន័យទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ស្របតាមការកំណត់នៅក្នុងមាត្រា១៩ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីតួនាទីភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋដល់អ្នកពាក់ព័ន្ធ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់យន្តការនេះ សម្រាប់សម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត។ ជាមួយនេះថ្នាក់ដឹកនាំរាជធានី ខេត្ត ត្រូវផ្តល់លទ្ធភាពជូនប្រធានការិយាល័យប្រជាពលរដ្ឋដើម្បីបញ្ជាបការផ្សព្វផ្សាយ អំពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំ ឬវេទិកាសាធារណៈនានាដែលរៀបចំឡើងដោយរដ្ឋបាលរាជធានី ខេត្ត

- រដ្ឋបាលរាជធានី ខេត្ត ត្រូវធានាឱ្យមានការការពារដល់ប្រធាន អនុប្រធាន និងបុគ្គលិកការិយាល័យប្រជាពលរដ្ឋពីការគំរាមកំហែងនានាក្នុងដំណើរការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ជាពិសេស នៅក្នុងដំណើរការស៊ើបអង្កេត និងសម្រុះសម្រួលដោះស្រាយបណ្ដឹង
- រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ដល់ប្រាក់បេសកកម្មដល់ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឱ្យស្មើនឹងប្រាក់បេសកកម្មរបស់ប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត។ ចំពោះប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្តត្រូវផ្ដល់ប្រាក់បេសកកម្មឱ្យបានស្មើនឹងប្រាក់បេសកកម្មរបស់នាយក និងនាយករងទីចាត់ការនៃរដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្ត ត្រូវបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ដែលទទួលបានពីការផ្ដល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ជូនដល់ប្រធាន អនុប្រធាន និងបុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋ ដើម្បីឧបត្ថម្ភលើកទឹកចិត្តដល់យន្តការសម្រុះសម្រួលដោះស្រាយបណ្ដឹងនេះ។

អាស្រ័យហេតុនេះ សូម**ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ និងលោក លោកស្រី** ទទួលនូវការរាប់អានអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**<u>ចម្លងជូន៖</u>**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ កាលប្បវត្តិ